**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពីការរៀបចំកិច្ចប្រជុំលើកទី១ គណៈកម្មការចម្រុះនៃកិច្ចសហប្រតិបត្តិការលើវិស័យ**
**សេដ្ឋកិច្ចកម្ពុជា-ហុងគ្រីតាមរយៈប្រព័ន្ធវីដេអូ**

យោងតាមស្មារតីនៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលហុងគ្រី ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ដែលបានចុះហត្ថលេខាដោយឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា និងឯកឧត្តម **ពីទើ ហ្ស៊ីយ៉ាតូ** រដ្ឋមន្ត្រីក្រសួងការបរទេស និងពាណិជ្ជកម្មហុងគ្រី កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩ អំឡុងពេលទស្សនកិច្ចជាផ្លូវការរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅទីក្រុងប៊ុយដាប៉េស ប្រទេសហុងគ្រី ភាគីទាំងពីរបានឯកភាពគ្នាក្នុងការរៀបចំបង្កើតគណៈកម្មការចម្រុះនៃកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ចកម្ពុជា-ហុងគ្រី ដើម្បីពង្រឹងមិត្តភាព និងលើកកម្ពស់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងប្រទេសទាំងពីរ។

កិច្ចប្រជុំនេះ ត្រូវរៀបចំនៅ**ថ្ងៃទី២០-២១ ខែមករា ឆ្នាំ២០២១** តាមរយៈប្រព័ន្ធវីដេអូ ( Virtual Conference ) នៅទីស្តីការក្រសួងពាណិជ្ជកម្ម រាជធានីភ្នំពេញ ក្រោមអធិបតីភាព លោកជំទាវ **ទឹករ៉េត កំរេខ** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មកម្ពុជា និងឯកឧត្តម **អ៊ីស្វាន់ ចូ** ( István Joó ) អនុរដ្ឋមន្ត្រីទទួលបន្ទុកវិស័យអភិវឌ្ឍការនាំចេញនៃក្រសួងការបរទេស និងពាណិជ្ជកម្មហុងគ្រី ដោយមានការអញ្ជើញចូលរួមពីមន្ត្រីជាន់ខ្ពស់មកពីក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ដែលជាសមាជិកគណៈកម្មការចម្រុះនេះ។

គោលបំណងនៃកិច្ចប្រជុំគឺ ដើម្បីជំរុញការអនុវត្តកិច្ចព្រមព្រៀង និងអនុស្សារណៈដែលបានចុះហត្ថលេខាកន្លងមក និងពិនិត្យតាមដានវឌ្ឍនភាពការងាររវាងភាគីទាំងពីរ។

កិច្ចប្រជុំនឹងពិភាក្សាអំពីកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗដូចជា៖ (១) ពាណិជ្ជកម្ម និងសេដ្ឋកិច្ច (២) គម្រោងឥណទាន ( Tied Aid Credit Cooperation ) (៣) កសិកម្ម សន្តិសុខស្បៀង និងវារីវប្បកម្ម (៤) ការគ្រប់គ្រងធនធានទឹក (៥) វិស័យអប់រំ យុវជន និងកីឡា (៦) វប្បធម៌ (៧) ទេសចរណ៍ (៨) ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង(៩) អាកាសចរស៊ីវិល។

ថ្ងៃចន្ទ ០៥កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម